**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

NATIONAL SOCIAL ASSISTANCE FUND
**មូលនិធិជាតិជំនួយសង្គម**

SOCIAL PROTECTION IN CAMBODIA

# សេចក្តីជូនដំណឹង
## ស្តីពី
## លទ្ធផលនៃការអនុវត្តកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ សម្រាប់ខែមេសា ឆ្នាំ២០២៥ និងការបើកសាច់ប្រាក់ សម្រាប់ខែឧសភា ឆ្នាំ២០២៥

កាលពីថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០២៣ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការនូវគោលការណ៍ណែនាំស្តីពីក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ និងដាក់ឱ្យអនុវត្តកម្មវិធីជាផ្លូវការនៅខែមេសា ឆ្នាំ២០២៤។ ជាមួយគ្នានេះដែរ មូលនិធិជាតិជំនួយសង្គម ដែលជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ស្ថិតក្រោមអាណាព្យាបាលបច្ចេកទេសរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងអាណាព្យាបាលហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក៏បានចាប់ផ្តើមដំណើរការអនុវត្តកម្មវិធីនៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៤ មកដល់បច្ចុប្បន្ន។

មូលនិធិជាតិជំនួយសង្គមមានកិត្តិយស សូមជម្រាបជូនសាធារណជន មេត្តាជ្រាបថា គិតត្រឹមថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៥ វេលាម៉ោង ១៧:០០ ការបើកផ្តល់សម្រាប់ ខែមេសា ឆ្នាំ២០២៥ ត្រូវបានបញ្ចប់ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

| ចំនួនគ្រួសារទទួលបានប្រាក់ឧបត្ថម្ភ | មនុស្សវ័យចាស់អាយុពី៦០ឆ្នាំឡើង | ជនមានពិការភាព | ជនផ្ទុកមេរោគនិងជំងឺអេដស៍ | សិស្សានុសិស្ស | ស្ត្រីមានផ្ទៃពោះនិងកុមារអាយុក្រោម ២ឆ្នាំ | ទឹកប្រាក់សរុប(រៀល) |
|---|---|---|---|---|---|---|
| 697,541 | 333,719 | 50,673 | 9,426 | 424,669 | 5,071 | 47,152,938,000 |

(សែសិបប្រាំពីរប៊ីលាន មួយរយហាសិបពីរលាន ប្រាំបួនរយសាបសិបប្រាំបីពាន់រៀលគត់)

សរុបការចំណាយលើការអនុវត្តកម្មវិធីចាប់ពីថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៥ អស់ថវិការដ្ឋ **៤៧២,១៥៩,០៨០,០០០រៀល (បួនរយចិតសិបពីរប៊ីលាន មួយរយហាសិបប្រាំបួនលាន ប៉ែតសិបពាន់រៀលគត់) ស្មើនឹង ១១៨.០៤ លានដុល្លារអាមេរិក។**

ព្រមជាមួយគ្នានេះផងដែរ សម្រាប់ការបើកផ្តល់ប្រាក់ឧបត្ថម្ភ ខែឧសភា ឆ្នាំ២០២៥ នឹងចាប់ផ្តើមពីថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៥ រហូតដល់ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២៥ នឹងត្រូវអនុវត្តតាមនីតិវិធី ដូចខាងក្រោម៖

- ចំពោះគ្រួសារ និងជនងាយរងគ្រោះ ដែលបានចុះឈ្មោះចូលកម្មវិធីមុនថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៥ រួចហើយ សូមអញ្ជើញទៅបើកប្រាក់ឧបត្ថម្ភនៅតាមបញ្ជរវីងណាមួយដោយមិនតម្រូវឱ្យទៅសាលាឃុំ សង្កាត់ សារជាថ្មីទៀតទេ
- ចំពោះគ្រួសារក្រីក្រ និងជនងាយរងគ្រោះ ដែលមានបណ្ណសមធម៌មានសុពលភាព ហើយមិនទាន់បានចុះឈ្មោះ និងគ្រួសារក្រីក្រដែលទើបទទួលបានបណ្ណសមធម៌ថ្មី សូមអញ្ជើញទៅចុះឈ្មោះនៅសាលា ឃុំ សង្កាត់ ណាមួយ ចាប់ពីថ្ងៃជូនដំណឹងនេះ រហូតដល់ ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២៥ ដើម្បីទទួលបានការឧបត្ថម្ភសាច់ប្រាក់ ចាប់ពីថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៥ តទៅ
- ពេលទៅបើកប្រាក់ឧបត្ថម្ភ សម្រាប់ខែឧសភា ឆ្នាំ២០២៥ នៅតាមបញ្ជរវីង តម្រូវឱ្យអ្នកទទួលផលត្រូវភ្ជាប់ទៅជាមួយនូវឯកសារពាក់ព័ន្ធដូចគ្នានឹងការបើកប្រាក់ឧបត្ថម្ភលើកមុនៗផងដែរ និងត្រូវចងចាំលេខសម្ងាត់ (បណ្ណសមធម៌មានសុពលភាព និងអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ)
- ករណីភ្លេចលេខសម្ងាត់ សូមទំនាក់ទំនងអ្នកទទួលបន្ទុកកម្មវិធីនៅតាមឃុំ សង្កាត់ ឬ សាខាមូលនិធិជាតិជំនួយសង្គម រាជធានី ខេត្ត
- ចំពោះសិស្សានុសិស្សស្ថិតក្នុងគ្រួសារក្រីក្រមានបណ្ណសមធម៌ សូមប្រញាប់ទៅធ្វើការបញ្ជាក់ការចុះឈ្មោះចូលរៀនក្នុងប្រព័ន្ធនៅតាមសាលារៀនដែលខ្លួនកំពុងសិក្សា និងចុះឈ្មោះចូលកម្មវិធីអាហារូបករណ៍សិស្សក្រីក្រនៅបឋមសិក្សា និងមធ្យមសិក្សាសាធារណៈ នៃកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ នៅឃុំ សង្កាត់ ដោយភ្ជាប់ជាមួយបណ្ណសមធម៌មានសុពលភាព និងលិខិតបញ្ជាក់ចុះឈ្មោះចូលរៀន ដើម្បីអាចទទួលបានប្រាក់ឧបត្ថម្ភពីកម្មវិធី
- ចំពោះជនចាស់ជរាអាយុ ៦០ឆ្នាំឡើង និងជនមានពិការភាព ដែលមិនបានទៅធ្វើបច្ចុប្បន្នភាព នៅ ឃុំ សង្កាត់ គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៥ នឹងត្រូវចាក់ចេញពីកម្មវិធីដោយស្វ័យប្រវត្តិ (ដើម្បីទទួលបានអត្ថប្រយោជន៍ឡើងវិញ តម្រូវឱ្យអ្នកទទួលផលធ្វើការចុះឈ្មោះថ្មីចូលកម្មវិធីនៅឃុំ សង្កាត់ ម្តងទៀត)
- ការចុះឈ្មោះនៅតាម ឃុំ សង្កាត់ ឬ ការដកសាច់ប្រាក់នៅតាមបញ្ជរវីង អ្នកទទួលផលទាំងអស់មិនតម្រូវឱ្យមានការបង់ប្រាក់ ឬ កាត់កម្រៃណាមួយនោះឡើយ ព្រោះតម្លៃសេវាប្រតិបត្តិការរបស់អ្នកទទួលផលត្រូវបានរាជរដ្ឋាភិបាលចេញជំនួសរួចហើយសម្រាប់បញ្ជរវីង
- សូមប្រជាជនទាំងអស់កុំចាញ់បោកជនខិលខូចមួយចំនួន ដែលបានដើរឃោសនាបោកប្រាស់ថាក្នុងករណីប្រជាជនចង់បានបណ្ណសមធម៌ នោះតម្រូវឱ្យគ្រួសារក្រីក្រត្រូវបង់ប្រាក់ ដែលទង្វើខាងលើនោះមិនត្រឹមត្រូវនោះឡើយ ព្រោះការផ្តល់បណ្ណសមធម៌ ត្រូវបានធ្វើឡើងតាមនីតិវិធីនៃការកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ របស់ក្រសួងផែនការដោយមិនមានរើសអើងនិន្នាការនយោបាយ និងយកកម្រៃណាមួយនោះឡើយ គឺប្រកបដោយអភិក្រមជាមន្ត្រីបម្រើរាស្ត្រ
- ក្នុងករណីប្រជាពលរដ្ឋ ឬ សាធារណជន ពិនិត្យឃើញភាពមិនប្រក្រតីណាមួយក្នុងការអនុវត្តកម្មវិធី ឬ ដកសាច់ប្រាក់មិនបាននៅតាមបញ្ជរវីងណាមួយនោះ សូម សាធារណជន និងអ្នកទទួលផលទាំងអស់ ធ្វើការទំនាក់ទំនងជាមួយអ្នកកាន់កម្មវិធីនៅតាមឃុំ សង្កាត់ ឬ សាខាមូលនិធិជាតិជំនួយសង្គម ឬ មន្ទីរផែនការ រាជធានី ខេត្តនីមួយៗ ឬ តាមរយៈ ប្រព័ន្ធទូរស័ព្ទព័ត៌មានទាន់ហេតុការណ៍របស់ មូលនិធិជាតិជំនួយសង្គម លេខ (០៩២ /០១៥) ២១៩ ៨៨៨

- ក្នុងករណីសាធារណជន ពិនិត្យឃើញមានការដាក់បញ្ចាំ ឬ ទទួលបញ្ចាំ បណ្ណសមធម៌ នោះ សូមសាធារណជនរាយការណ៍ជូនអ្នកកាន់កម្មវិធីនៅតាមឃុំ សង្កាត់ ឬ នៅសាខាមូលនិធិជាតិជំនួយសង្គម ឬ មន្ទីរផែនការ រាជធានី ខេត្តនីមួយៗ ឬ តាមរយៈប្រព័ន្ធទូរស័ព្ទព័ត៌មានទាន់ហេតុការណ៍របស់ មូលនិធិជាតិជំនួយសង្គម លេខ (០៩២ /០១៥) ២១៩ ៨៨៨ ដើម្បីចាត់វិធានការតាមផ្លូវច្បាប់
- ស្នើសុំឱ្យអ្នកទទួលផលទាំងអស់ប្រើប្រាស់ថវិកា ដែលទទួលបានពីកម្មវិធីឱ្យបានត្រឹមត្រូវដោយចៀសវាងការប្រើប្រាស់ក្នុងគោលបំណងបម្រើឱ្យអបាយមុខផ្សេងៗ ដែលនាំឱ្យប៉ះពាល់ដល់ការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការផ្តល់ការអន្តរាគមន៍ជំនួយសង្គមជាសាច់ប្រាក់នេះ។ ក្នុងករណីពិនិត្យរកឃើញមានអ្នកទទួលផលដែលប្រើប្រាស់ខុសគោលដៅបែបនេះ ស្នើឱ្យអាជ្ញាធរមូលដ្ឋានធ្វើការអប់រំដល់អ្នកទទួលផលទាំងនោះជាលាយលក្ខណ៍អក្សរ បើក្នុងករណីអ្នកទទួលផលទាំងនោះនៅមិនរៀងចាលនោះទេ មេឃុំ-ចៅសង្កាត់ ត្រូវធ្វើការប្រជុំពិភាក្សាជាមួយក្រុមប្រឹក្សាក្នុងការធ្វើបច្ចុប្បន្នភាពបណ្ណសមធម៌នោះឡើងវិញ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន និងស្ថាប័នពាក់ព័ន្ធ ជាពិសេស គ្រួសារក្រីក្រ និងងាយរងគ្រោះ ទាំងអស់មេត្តាជ្រាប និងបន្តសហការអនុវត្ត ដើម្បីឱ្យកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារបន្តដំណើរការដោយរលូន និងទទួលបានជោគជ័យបន្តទៀត ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការផ្តល់ការអន្តរាគមន៍ជំនួយសង្គមដល់ប្រជាជន ពិសេស គ្រួសារក្រីក្រ និងងាយរងគ្រោះ ដោយមិនទុកប្រជាជនណាម្នាក់ចោល ហើយមិនមានការយកចិត្តទុកដាក់ពីរដ្ឋនោះឡើយ ។/.

ថ្ងៃសុក្រ ១១កើត ខែអស្សុជ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ, ថ្ងៃទី ៣ ខែតុលា ឆ្នាំ២០២៥

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រុមប្រឹក្សាភិបាល នៃមូលនិធិជាតិជំនួយសង្គម
- គ្រប់សាលារាជធានី-ខេត្ត
- ធនាគារវីង (ខេមបូឌា) ភីអិលស៊ី
- ឯកសារ កាលប្បវត្តិ